**សេចក្តីថ្លែងការណ៍លើសំណើសុំក្រោមមាត្រា៨ នៃអនុសញ្ញាអូតាវ៉ា**
**កិច្ចប្រជុំលើកទី២២ នៃរដ្ឋភាគីអនុសញ្ញាអូតាវ៉ា**
**ទីក្រុងហ្សឺណែវ ប្រទេសស្វីស**
**ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៥**

*លោកជំទាវប្រធាន និងអង្គប្រជុំជាទីមេត្រី!*

កម្ពុជា សូមថ្លែងអំណរគុណ ចំពោះឱកាសធ្វើការបកស្រាយចំពោះបញ្ហានេះ។ ខ្ញុំសូមអនុញ្ញាតចាប់ផ្តើម ជាមួយនឹងសំណួរដោយស្មោះត្រង់មួយ ទៅកាន់អង្គប្រជុំទាំងមូលៈ

*"ក្នុងប្រវត្តិសាស្ត្រនៃអនុសញ្ញានេះ តើប្រទេសណា ដែលធ្លាប់ប្រើប្រាស់កម្លាំងយោធាវាយប្រហារទៅលើប្រទេសជិតខាងរបស់ខ្លួន ដោយមូលហេតុឧប្បត្តិហេតុផ្ទុះមីនដែលមិនទាន់បានស៊ើបអង្កេត និងផ្ទៀងផ្ទាត់ច្បាស់លាស់?"*

វាពិតជាគួរឱ្យសោកស្តាយ ដែលកម្ពុជាត្រូវទទួលរងគ្រោះដោយសារបញ្ហានេះ។ ប៉ុន្មានខែកន្លងមកនេះ កម្ពុជាបានទទួលរងគ្រោះធ្ងន់ធ្ងរ ដោយសារសកម្មភាពយោធាថៃ ដែលជាប្រទេសជិតខាងគ្នា ដោយប្រើប្រាស់ការចោទប្រកាន់គ្មានមូលដ្ឋាន និងគ្មានការស៊ើបអង្កេតច្បាស់លាស់ ជុំវិញបញ្ហាមីន។ កាន់តែគួរឱ្យព្រួយបារម្ភនោះគឺ រហូតមកដល់បច្ចុប្បន្ន ថៃនៅតែបន្តប្រើប្រាស់ការចោទប្រកាន់ដែលគ្មានការពិត គ្មានការស៊ើបអង្កេតច្បាស់លាស់ មិនឯករាជ្យ និងមិនស្របតាមមូលដ្ឋានច្បាប់នេះ ដើម្បីបង្កើនភាពតានតឹងជាមួយកម្ពុជា។

ការចោទប្រកាន់ដែលគ្មានមូលដ្ឋាន នឹងមិននាំមកនូវសុខសន្តិភាពនោះទេ ផ្ទុយទៅវិញ វានឹងបំផ្លាញទំនុកចិត្តរវាងគ្នានិងគ្នា និងឆ្លុះបញ្ចាំងពីការចាកចេញ ពីគោលការណ៍នៃសុចរិតភាព យុត្តិធម៌ និងភាពអ្នកជិតខាងល្អ ដែលជាមគ្គុទេសក៍នាំផ្លូវរបស់រដ្ឋភាគីទាំងអស់។

*លោកជំទាវប្រធាន!*

ស្មារតីដែលបានបង្កើតអនុសញ្ញានេះ គឺៈ ភាពជាដៃគូ ការសន្ទនា និងការប្តេជ្ញាចិត្តរួមគ្នាដើម្បីការពារជីវិត ស្តារសន្តិភាព និងកសាងពិភពលោកដែលប្រកបដោយសុវត្ថិភាព សម្រាប់មនុស្សជំនាន់ក្រោយ។ ក៏ប៉ុន្តែ វាគួរឱ្យសោកស្តាយ ដែលថៃបានព្យាយាមជ្រើសរើសយកយន្តការនៃមាត្រា៨.២ នៃអនុសញ្ញាអូតាវ៉ា ដោយរំលងមាត្រា៨.១។ សូមគូសបញ្ជាក់ថា យន្តការមាត្រា៨.២ នឹងត្រូវប្រើប្រាស់លុះណាតែ ការដោះស្រាយបញ្ហាតាមរយៈកិច្ចសន្ទនាដោយសន្តិវិធី ស្របតាមយន្តការមាត្រា៨.១ ត្រូវបានប្រើប្រាស់អស់ពីលទ្ធភាព។

ទង្វើនេះ គឺជាការបង្ហាញអំពីភាពមិនស្មោះត្រង់ និងមិនមែនជាស្មារតីកិច្ចសហប្រតិបត្តិការ តែវាជាការបង្កឱ្យមានការប្រឈមមុខដាក់គ្នា ហើយការប្រឈមមុខដាក់គ្នានេះ នឹងមិនដោះស្រាយបញ្ហាដោយសន្តិភាពឡើយ។

*លោកជំទាវប្រធាន!*

កម្ពុជាមានការសោកស្តាយ ដែលបញ្ហានេះត្រូវបានលើកយកមកដោះស្រាយ នៅក្នុងកិច្ចប្រជុំដ៏សំខាន់នេះ។ វាគួរតែត្រូវបានដោះស្រាយ តាមរយៈការសន្ទនាដោយសន្តិវិធី និងយន្តការដែលមានស្រាប់ រវាងប្រទេសទាំងពី ក្នុងនាមជាប្រទេសជិតខាងល្អ ដែលមានប្រវត្តិសាស្ត្ររួមគ្នា ជាច្រើនសតវត្សមកហើយ។ កម្ពុជា មិនចង់ឃើញវេទិកានេះ ត្រូវបានប្រែក្លាយឱ្យទៅជាសាលាក្តី ឬវេទិកាសម្រាប់ការប្រឈមមុខដាក់គ្នា ក្នុងផ្លូវនយោបាយនោះទេ។ វេទិកានេះ គួរតែជាវេទិកាដែលរដ្ឋភាគីធ្វើការរួមគ្នា ដោយស្មោះត្រង់ និងគោរពគ្នាទៅវិញទៅមក ដើម្បីដោះស្រាយបញ្ហាតាមរយៈកិច្ចសន្ទនា និងដោយសន្តិវិធី។

*លោកជំទាវប្រធាន!*

កម្ពុជាបានរងគ្រោះធ្ងន់ធ្ងរដោយសារមីន ហេតុនេះ យើងបានប្តេជ្ញាដាច់ខាតចំពោះអនុសញ្ញានេះ។ យើងមិនបានប្រើប្រាស់មីនប្រឆាំងមនុស្សចាប់តាំងពីចូលជារដ្ឋភាគីអនុសញ្ញា ហើយយើងនឹងមិនប្រើប្រាស់ជាដាច់ខាត។ សមិទ្ធផលរបស់កម្ពុជា ដែលត្រូវបានទទួលស្គាល់ជាសកល បង្ហាញច្បាស់ពីភាពឈានមុខក្នុងកិច្ចការមនុស្សធម៌របស់កម្ពុជា ប្រតិបត្តិការបោសសម្អាតមីនទូលំទូលាយ និងការគាំទ្ររបស់កម្ពុជា ទៅកាន់ប្រទេសរងគ្រោះផ្សេងទៀត។ ភាពឈានមុខរបស់កម្ពុជា ក្នុងកិច្ចការមនុស្សធម៌ ត្រូវបានទទួលស្គាល់ទូទាំងពិភពលោក។ គ្មានទង្វើដែលមានចេតនានយោបាយណាមួយ អាចកែប្រែការពិតនេះបានឡើយ។

កម្ពុជា ចូលរួមសោកស្តាយដល់អ្នកដែលរងរបួស ក្នុងឧប្បត្តិហេតុផ្ទុះមីនថ្មីៗនេះ ប៉ុន្តែយើងមិនអាចមើលរំលងការពិតនោះឡើយ ហើយកម្ពុជានឹងការពារបូរណភាពរបស់ខ្លួន និងបន្តអំពាវនាវឱ្យប្រកាន់ខ្ជាប់នូវយន្តការស៊ើបអង្កេតរួមគ្នា ប្រកបដោយកិច្ចសហប្រតិបត្តិការ និងផ្អែកលើភស្តុតាង។

សូមយើងធ្វើការរួមគ្នា ដើម្បីស្វែងរកការពិត។ សូមយើងរក្សាឱ្យបាននូវស្មារតីសហប្រតិបត្តិការរបស់អនុសញ្ញានេះ។ សូមយើងជ្រើសយកការសន្ទនាដោយសន្តិភាព ជំនួសឱ្យការប្រឈមមុខដាក់គ្នា។ សូមយើងរួមគ្នា ធានាឱ្យបាននូវសន្តិភាព និងស្ថិរភាព ជូនដល់ប្រជាជនរបស់យើងទាំងអស់គ្នា ទាំងពេលបច្ចុប្បន្ន និងសម្រាប់មនុស្សជំនាន់ក្រោយ។

កម្ពុជា និងថៃ គឺជាអ្នកជិតខាងគ្នាអស់ជាច្រើនសតវត្សមកហើយ ហើយយើងនឹងនៅតែជាអ្នកជិតខាងគ្នា ជាច្រើនសតវត្សទៅមុខទៀត។

ពាក្យចាស់ពោលថា គ្រួសារអាចនឹងបែកគ្នា តែអ្នកជិតខាង នឹងមិនអាចបែកគ្នាឡើយ ដូច្នេះសូមឱ្យយើងស្រឡាញ់អ្នកជិតខាងរបស់យើង ដូចជាយើងស្រលាញ់ខ្លួនឯង។

សូមអរគុណលោកជំទាវប្រធាន។